# បទព្រហ្មគីត

| | |
|---|---|
| សង្គហធម៌ ៤ | គ្រឹះមាំមួនជួយសង្គ្រោះ |
| ពួកមនុស្សឲ្យបានរស់ | សុខសប្បាយគ្រប់ ៗ គ្នា ។ |
| ទី ១ ត្រូវចែកទាន | កុំកំណាញ់ក្រៅតម្រា |
| គិតត្រឹមតែអាត្មា | និងបក្សពួកញាតិផងខ្លួន។ |
| ត្រូវគិតអ្នកដទៃ | ចែកទានលៃឲ្យសមសួន |
| កុំចង់រស់តែខ្លួន | មិនសុខទេណាអ្នកអើយ ។ |
| ទី ២ ពេលធ្វើទាន | មានសំដីសាសងឆ្លើយ |
| ពីរោះផ្អែមឆ្ងាញ់ហើយ | ទើបអ្នកផងគេចូលចិត្ត ។ |
| ទី ៣ ធ្វើប្រយោជន៍ | ទោះល្អិតល្អោច ឬ ប្រណីត |
| ជួយធ្វើដោយពេញចិត្ត | នឹកអាណិតដល់អ្នកក្រ ។ |
| ទោះទៅកាន់ទីណា | តែងឧស្សាហ៍ធ្វើការល្អ |
| មិនបាច់គេអង្វរ | ដោយស្មោះសរផុតបង្ខំ ។ |
| ទី ៤ ដាក់ខ្លួនស្មើ | មិនដែលធ្វើឫកអ្នកធំ |
| សុភាពល្អសមរម្យ | គួរនិយមគួរសេពគប់ ។ |
| បើបានធ្វើមេបា | សង្ឃឹមថាបានជាម្ចប់ |
| ត្រដាក់ទាំងថ្ងៃយប់ | គេគោរពគ្រប់គ្នាផង ។ |
| ហេតុនេះអស់លោកអ្នក | ស្តាប់ឲ្យជាក់ចេះចាំចង |
| ធ្វើតាមកុំឲ្យហ្មង | បានសុខហោងគ្រប់គ្នាអើយ៕ |

**ចាក ព្រះត្រៃលក្ខណ៍ និង សង្គហធម៌**

**បុណ្យ ១០០ ថ្ងៃ លោក នេត្រ គួន ឆ្នាំ ២០០១**

| | | |
|---|---|---|
| សង្គហៈ | ធម៌ជាលក្ខ | គោលបួនយ៉ាង |
| ជាតឹកតាង | បដិវត្តន៍ | ជួយសង្គ្រោះ |
| សម្រាលទុក្ខ | បង្កើតសុខ | ដល់មនុស្ស |
| ឲ្យបានរស់ | សុខសប្បាយ | គ្រប់ ៗ គ្នា ។ |
| ត្រូវចែកទាន | ឲ្យគេបាន | រស់សុខផង |

| | | |
|---|---|---|
| ជាចំណង | សាមគ្គី | ញាតិអាត្មា |
| កុំកំណាញ់ | ឬខ្ជះខ្ជាយ | ក្តីកាមា |
| ចាយហ៊ឺហា | សុខសប្បាយ | តែគ្នាឯង ។ |
| ព្រះសម្ពុទ្ធ | ជាមកុដ | ផុតលោកា |
| ត្រាស់ទេសនា | ប្រៀនប្រដៅ | យ៉ាងជាក់ស្តែង |
| បាយមួយដុំ | បើគេសុំ | ត្រូវតែបែង |
| ចែកគេឯង | ឲ្យបានស៊ី | ចុកសុខផង ។ |
| ស៊ីតែឯង | មិនគិតក្រែង | ស្មានថាសុខ |
| ថ្ងៃទៅមុខ | ទុក្ខអនេក | ពេកកន្ទង |
| ភ្ញាក់រលឹក | នឹកដល់ពាក្យ | ព្រះច្បាស់ច្បង |
| ចែកទានផង | ទើបគួរគាប់ | ជាប់និស្ស័យ ។ |
| ពេលឲ្យទាន | ត្រូវតែមាន | ពាក្យពីរោះ |
| កុំទ្រគោះ | ពាក្យខ្មោះខ្មួរ | ដួពេកក្រៃ |
| គេមិនចង់ | ទទួលទេ | ទានអប្រិយ |
| បើសំដី | ទន់ផ្អែមល្ហែម | ទើបចង់បាន ។ |
| ពាក្យទ្រគោះ | មិនពីរោះ | កើតអមិត្ត |
| ពីរោះពិត | ចងជាប់ចិត្ត | មិត្តកល្យាណ |
| យើងជាមនុស្ស | ពោលពីរោះ | គ្រប់ ៗប្រាណ |
| ទើបសមឋាន | បានកើតជា | សត្វប្រសើរ ។ |
| ធ្វើប្រយោជន៍ | កុំចាំពឹង | តែលើទ្រព្យ |
| ខ្លួនយើងរាប់ | ថាជាទ្រព្យ | គាប់ណាស់តើ |
| ជួយអ្វីបាន | ជួយសាងសុខ | គេបណ្តើរ |
| ខ្លួនហ្នឹងតើ | ចាត់ជាទ្រព្យ | គាប់ពេកក្រៃ ។ |
| ជួយដោយកាយ | វាចាចិត្ត | គំនិតល្អ |
| ចិត្តស្មោះសរ | ជួយសាងសុខ | រៀងរាល់ថ្ងៃ |

| | | |
|---|---|---|
| កុំនៅស្ងៀម | មើលបំណាំ | ធ្វើវាហី |
| ចង្អៀតដី | គេមិនរាប់ | ផាប់អសារ ។ |
| សង្គ្រោះគេ | កុំវាយឫក | ចង់ធ្វើធំ |
| គេមិនសម | មិនគប់រក | យកជាគ្នា |
| ទុកដាក់ខ្លួន | យ៉ាងសមសួន | តាមធម្មតា |
| គេត្រូវការ | គេគោរព | ដោយចិត្តស្មោះ។ |
| អ្នកឫកធំ | នាំធ្វើអ្វី | មិនបានការ |
| គេចាត់ថា | ជាមនុស្ស | អសប្បុរស |
| គេមិនព្រម | រួបរួមចូល | ជាមួយសោះ |
| គេស្មគ្រ័ស្មោះ | ជាមួយអ្នក | ស្មើ ៗ ភាព ។ |
| ហេតុនេះហើយ | ត្រូវតែឈប់ | វាយឫកធំ |
| វាមិនថ្កុំ | ថ្កើងរុងរឿង | នាំថោកទាប |
| សូវធ្វើឫក | ស្មើ ៗ គ្នា | យ៉ាងសុភាព |
| ទើបគេក្រាប | លើកតម្កើង | ឲ្យឡើងខ្ពស់ ។ |
| នេះជាគោល | សង្គហ: | ធម៌ថ្លៃថ្លា |
| ព្រះសាស្តា | បរមគ្រូ | ដ៏ទ្រង់យស |
| សម្តែងទុក | ឲ្យយើងយក | ទៅសង្គ្រោះ |
| ជួយមនុស្ស | ឲ្យបានរស់ | សុខសប្បាយ ៕ |